**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
លេខ ២៣១ ឧវបន.កសក.ប្រក

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំនៅកម្ពុជា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកសិកម្មជាអគ្គនាយកដ្ឋានកសិកម្ម ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ១៦៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានពូជដំណាំចំណុះអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ ១.-**

ប្រកាសអន្តរក្រសួងនេះមានគោលដៅកំណត់យន្តការ និងលក្ខខណ្ឌក្នុងការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំនៅកម្ពុជា ដើម្បីធានានូវការគ្រប់គ្រង ការលើកទឹកចិត្ត និងការអភិវឌ្ឍពូជថ្មីនៃដំណាំដោយនិរន្តរភាព ព្រមទាំងការលើកកម្ពស់ផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន។

**ប្រការ ២.-**

ប្រកាសអន្តរក្រសួងនេះ មានវិសាលភាពអនុវត្តលើការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

វាក្យស័ព្ទដែលប្រើក្នុងប្រកាសនេះ ត្រូវបានបកស្រាយដូចខាងក្រោម៖

**១-ច្បាប់** សំដៅដល់ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

**២-ពូជ** (Variety) សំដៅដល់រាល់ប្រភេទពូជដំណាំ ឬក្រុមផ្សេងៗនៃប្រភេទពូជដំណាំណាមួយ ដែលមានលក្ខណៈដូចគ្នា និងធ្វើឱ្យឃើញថាប្លែកពីរុក្ខជាតិដទៃទៀតក្នុងប្រភេទពូជដំណាំតែមួយក្នុងលក្ខណៈ

មួយឬច្រើន ហើយដែលលក្ខណៈទាំងនេះនៅតែអាចរក្សាបាន ដើម្បីយកទៅប្រើប្រាស់ធ្វើជាពូជដំណាំបាន ឬការបង្កាត់ដោយសរីរាង្គដទៃទៀត។

៣-**ពូជថ្មីនៃដំណាំ** (New Variety) សំដៅដល់ពូជដំណាំទាំងឡាយដែលទើបនឹងរកឃើញ និងអភិវឌ្ឍន៍ថ្មីៗដោយរុក្ខជំរើសវិទូ ឬអ្នកបង្កាត់ពូជដំណាំ និងកាន់កាប់ផ្តាច់មុខយ៉ាងទូលំទូលាយក្នុងរយៈពេលមួយជាក់លាក់ ដែលកំណត់ដោយច្បាប់។

៤-**ពន្ធុ** (Gene) សំដៅដល់ក្រុមនៃក្រូម៉ូសូម ដែលជាឯកតាបន្តពូជអាចបញ្ជូនព័ត៌មានតំណពូជពីជំនាន់មួយទៅជំនាន់មួយក្រោយទៀត ឬពីមេបាទៅកូន។

៥-**ឯកសណ្ឋានភាព** (Uniformity) សំដៅលើពូជដំណាំដែលអាចរក្សាបានគ្រប់គ្រាន់នូវចរិតលក្ខណៈពាក់ព័ន្ធរបស់ពូជ ទោះបីពូជដំណាំនោះត្រូវបានផលិតតាមរយៈភេទ ឬអភេទក្តី។

៦-**ស្ថិរភាព** (Stability) សំដៅលើពូជដំណាំដែលចរិតលក្ខណៈចាំបាច់របស់វាគ្មានការប្រែប្រួលនៅគ្រប់ដំណាក់កាលនៃវដ្តលូតលាស់ និងជំនាន់នីមួយៗ។

៧-**ភ្នាក់ងារតំណាង** (Agent) សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងបំពេញកិច្ចការចំពោះមុខក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ភ្នាក់ងារតំណាងត្រូវមានទីលំនៅអចិន្ត្រៃយ៍ ឬកំពុងប្រកបវិជ្ជាជីវៈនៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## សមត្ថកិច្ចអនុវត្ត

**ប្រការ ៤.-**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាស្ថាប័នទទួលខុសត្រូវក្នុងការចុះបញ្ជីការពារពូជថ្មីនៃដំណាំ មានតួនាទីដូចខាងក្រោម៖

១-ផ្តល់ការការពារសិទ្ធិអ្នកបង្កាត់ពូជថ្មីនៃដំណាំ

២-ផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ

៣-ប្រកាសមោឃភាព ឬលុបចោល

៤-ទទួលការចុះបញ្ជីផ្លាស់ប្តូរ ឬលុបចោលពូជថ្មីនៃដំណាំ

៥-ចេញអាជ្ញាប័ណ្ណបញ្ជា

៦-កត់ត្រាកិច្ចសន្យាអាជ្ញាប័ណ្ណ និង

៧-ពិនិត្យភាពថ្មីនៃពូជដំណាំ។

**ប្រការ ៥.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាស្ថាប័នទទួលខុសត្រូវធ្វើពិសោធន៍លើពូជថ្មីនៃដំណាំ ដែលបានបញ្ជូនមកពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីធ្វើការសិក្សាវាយតម្លៃអំពីលទ្ធផល

បច្ចេកទេសលើពូជថ្មីនៃដំណាំតាមដំណាក់កាលនៃវដ្តលូតលាស់ និងជំនាន់នីមួយៗ (ភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថិរភាព) ហើយត្រូវផ្ញើលិខិតបញ្ជាក់លទ្ធផលបច្ចេកទេសដែលបានសិក្សាវាយតម្លៃរួច មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ វិញដើម្បីផ្តល់វិញ្ញាបនបត្រការពារពូជថ្មីនៃដំណាំជូនម្ចាស់សិទ្ធិ។

### ប្រការ ៦.-

ការត្រួតពិនិត្យលើការដាក់ឈ្មោះពូជថ្មីនៃដំណាំ ត្រូវសហការរវាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី ៣
## លក្ខខណ្ឌនៃការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំ

### ប្រការ ៧.-

ពូជថ្មីនៃដំណាំដែលទទួលបាននូវសិទ្ធិការពារត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ភាពថ្មី
- ភាពខុសប្លែក
- ឯកសណ្ឋានភាព
- ស្ថិរភាព។

### ប្រការ ៨.-

ពូជដំណាំដែលអាចចាត់ទុកថាថ្មី លុះត្រាតែពុំទាន់បានដាក់លក់ ឬចរាចរលើទីផ្សារកន្លងមក ប៉ុន្តែដោយមានការឯកភាពពីអ្នកបង្កាត់ពូជ ពូជថ្មីនៃដំណាំនោះត្រូវបានដាក់លក់ ឬចរាចរលើទីផ្សារ ក្នុងរយៈពេលមិនលើសពី ១(មួយ)ឆ្នាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមិនលើសពី៦(ប្រាំមួយ)ឆ្នាំ ចំពោះដំណាំវល្លិ និងដំណាំឈើ និងមិនលើសពី៤(បួន)ឆ្នាំ ចំពោះគ្រប់ដំណាំផ្សេងទៀត នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដោយគិតមកដល់ថ្ងៃដាក់ពាក្យស្នើសុំសិទ្ធិការពារ។

### ប្រការ ៩.-

ពូជដំណាំដែលអាចចាត់ទុកថាមានភាពខុសប្លែកពីគេ លុះត្រាតែមានភាពខុសគ្នាដាច់ស្រឡះពីពូជឯទៀតដែលគេស្គាល់ជាទូទៅ ត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំសិទ្ធិ ឬកាលបរិច្ឆេទសិទ្ធិអាទិភាព។

### ប្រការ ១០.-

ពូជដំណាំដែលអាចចាត់ទុកថាមានឯកសណ្ឋានភាព លុះត្រាតែអាចរក្សានូវឯកសណ្ឋានភាព គ្រប់គ្រាន់នូវចរិតលក្ខណៈពាក់ព័ន្ធរបស់ពូជ ទោះបីជាពូជដំណាំនោះត្រូវបានផលិតតាមរយៈភេទ ឬអភេទក្តី។

### ប្រការ ១១.-

ពូជដំណាំដែលអាចចាត់ទុកថាមានស្ថិរភាព លុះត្រាតែចរិតលក្ខណៈចាំបាច់របស់វា គ្មានការប្រែប្រួលនៅគ្រប់ដំណាក់កាលនៃវដ្តលូតលាស់ និងជំនាន់នីមួយៗ។

### ប្រការ ១២.-

ការដាក់ពាក្យសុំសិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវដាក់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ ១៣.-**

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស ដើម្បីកំណត់ភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថិរភាព ត្រូវធ្វើនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ១៤.-**

វិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវផ្តល់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រោយពីទទួលបានលិខិតបញ្ជាក់លទ្ធផលនៃការសិក្សាវាយតម្លៃលក្ខណៈបច្ចេកទេស ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ១៥.-**

កម្រៃសេវាសាធារណៈពាក់ព័ន្ធក្នុងការចុះបញ្ជី និងរក្សាសុពលភាពប្រចាំឆ្នាំនៃសិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ កម្រៃសេវាសាធារណៈនេះត្រូវបង់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

កម្រៃសេវាកម្មបច្ចេកទេសពូជថ្មីនៃដំណាំត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ កម្រៃសេវាកម្មបច្ចេកទេស ត្រូវបង់នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ១៦.-**

ភ្នាក់ងារតំណាងត្រូវបំពេញលក្ខខណ្ឌជាអាទិ៍ដូចខាងក្រោម៖

១-ការចាត់តាំងភ្នាក់ងារតំណាង ត្រូវធ្វើឡើងតាមរយៈលិខិតប្រគល់សិទ្ធិដែលចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ឬដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ប្រសិនបើអ្នកដាក់ពាក្យសុំលើសពីមួយនាក់។ អាសយដ្ឋានរបស់ភ្នាក់ងារតំណាងត្រូវចាត់ទុកថាជាអាសយដ្ឋានទាក់ទង ដើម្បីបញ្ជូនដំណឹងទៅបុគ្គលម្នាក់ ឬច្រើននាក់ ដែលបានចាត់តាំងភ្នាក់ងារតំណាងនោះ សម្រាប់គោលបំណងទាំងឡាយដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងប្រកាសអន្តរក្រសួងនេះ។

២-លិខិតប្រគល់សិទ្ធិឲ្យធ្វើជាភ្នាក់ងារតំណាង ដូចមានចែងក្នុងចំណុច១នៃប្រការនេះ ត្រូវដាក់ភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំ ឬដែលអាចប្រគល់ក្នុងរយៈពេលពីរ(២)ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំនោះ។

៣-ភ្នាក់ងារតំណាង ដែលដាក់ពាក្យស្នើសុំចុះបញ្ជីពូជថ្មីនៃដំណាំក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការទំនាក់ទំនងដាក់ពាក្យសុំ។

**ជំពូកទី៤**

**អវសានប្បញ្ញត្តិ**

**ប្រការ ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៨.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានគ្រប់អង្គភាព ដែលពាក់ព័ន្ធក្រោមឱវាទក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០២១.

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

***កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ***

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ